# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and the WSD Handa Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)

# របាយការណ៍ប្រចាំសប្តាហ៍លេខ ១

ចាប់តាំងពីអង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រមរបស់ខ្លួនក្នុងសំណុំរឿង០០២ វគ្គទី១ កាលពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤មក ក្នុងសវនាការលើបណ្តឹងសាទុក្ខលើកទី១ អង្គជំនុំជម្រះតុលាការកំពូលបានស្តាប់សក្ខីកម្មរបស់សាក្សីថ្មីចំនួនបីរូប។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា សហជនជាប់ចោទ លោក **នួន ជា** និងលោក **ខៀវ សំផន** មានពិរុទ្ធភាពលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលរួមមាន៖ ការធ្វើមនុស្សឃាត ការប្រព្រឹត្តអំពើអមនុស្សធម៌ ការជម្លៀសដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ ការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរដល់មនុស្សជាតិ ក្នុងដែនដីនៃប្រទេសកម្ពុជានៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងចុងឆ្នាំ១៩៧៧។[1] អង្គជំនុំជម្រះសាលាដំបូង បានដាក់ទោសសហជនជាប់ចោទទាំងពីរឲ្យជាប់គុកអស់មួយជីវិត។ ក្រុមមេធាវីការពារក្តី បានធ្វើបណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលាក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី២៩ ធ្នូ ឆ្នាំ២០១៤ ហើយលោក **នួន ជា** ក៏បានធ្វើបណ្តឹងស្នើសុំចំនួនប្រាំផ្សេងៗគ្នាផងដែរ ដើម្បីស្នើសុំដាក់ភស្តុតាងបន្ថែមក្នុងកិច្ចដំណើរការនីតិវិធីសវនាការលើដំណាក់ការនៃបណ្តឹងសាទុក្ខ។ លោក **នួន ជា** បានលើកឡើងនូវទឡ្ហីករណ៍ចំនួន ២២៣ សម្រាប់ប្តឹងសាទុក្ខ ហើយលោក **ខៀវ សំផន** បានលើកឡើងនូវទឡ្ហីករណ៍ចំនួន ១៤៨ សម្រាប់ប្តឹងសាទុក្ខ ដែលគ្របដណ្តប់លើការចោទប្រកាន់ពីកំហុសទាំងអង្គច្បាប់ និងអង្គហេតុ។[2] សហព្រះរាជ

---

[1] Trial Chamber, "Case 002/01 Judgment" (7 August 2014), E313 [hereinafter, **TRIAL CHAMBER JUDGMENT**].

[2] Nuon Chea, "Nuon Chea's Appeal Against the Judgment in Case 002/01" (29 December 2014), F16 [hereinafter, **NUON CHEA'S APPEAL**]; Khieu Samphan, "Mémoired'appel de la Défense de M.KHIEU Samphâncontre le jugementrendudans le process 002/01" (31 December 2014), F17/Corr.1. Khieu Samphan's initial appeal brief was

អាជ្ញា បានធ្វើបណ្តឹងសាទុក្ខយ៉ាងខ្លីមួយ ដែលស្នើសុំឲ្យដោះស្រាយតែលើការចោទប្រកាន់ថាមានកំហុសអង្គច្បាប់ ពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមិនអនុវត្តនូវទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម ដែលត្រូវបានគេស្គាល់ថាជា "ទម្រង់ទី៣" ជាប្រភេទមួយនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។[3]

បណ្តឹងសាទុក្ខរបស់ក្រុមការពារក្តី បានស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលកោះហៅសាក្សីមួយចំនួន ក្នុងនោះមានសាក្សីចំនួនបីរូបដែលត្រូវបានអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចស្តាប់សក្ខីកម្ម តាមសេចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ លើផ្នែកស្នើសុំដាក់ភស្តុតាងបន្ថែមរបស់លោក **នួន ជា**។[4] អង្គជំនុំជម្រះតុលាការកំពូល បានរៀបចំកាលវិភាគសម្រាប់សវនាការបឋមលើកទី១ ចាប់ពីថ្ងៃទី២ ដល់៦ ខែកក្កដា ឆ្នាំ២០១៥ ដែលជាការចាប់ផ្តើមបើកសវនាការលើបណ្តឹងសាទុក្ខរបស់ភាគីក្នុងសំណុំរឿង០០២ វគ្គទី១ ក៏ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូល បានផ្តោតជាពិសេសតែលើការរៀបចំសវនាការដើម្បីធ្វើការសួរដេញដោលទៅលើសាក្សីទាំងបីរូបដែលត្រូវបានកោះហៅឲ្យបង្ហាញខ្លួនតែប៉ុណ្ណោះ។ សាក្សីទាំងបីរូបនេះ បានផ្តល់សក្ខីកម្មក្នុងអំឡុងពេលសវនាការចំនួនបីថ្ងៃ ដែលភាគច្រើនពាក់ព័ន្ធនឹងផ្នែកជាច្រើននៃសាលក្រម ដែលបានរកឃើញនូវភស្តុតាងស្តីពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានកំណត់គោលដៅលើទាហាន និងមន្ត្រីរបបសាធារណរដ្ឋខ្មែរ ក្រោយពីការរំដោះនៅខែមេសា ឆ្នាំ១៩៧៥។ សាក្សីទីមួយ គឺលោក **សៅ វណ្ណ** (អត្តលេខ SCW-4) ត្រូវបានកោះហៅដើម្បីផ្តល់សក្ខីកម្មស្តីពីកិច្ចប្រជុំជាច្រើន ដែលគាត់ និងកម្មាភិបាលខ្មែរក្រហមដទៃទៀត ត្រូវបានបញ្ជាមិនឲ្យធ្វើបាបលើទាហាន **លន់ នល់**។ អង្គជំនុំជម្រះសាលាដំបូង បានយោងលើកំណត់ត្រាជាលាយលក្ខណ៍អក្សរនៃបទសម្ភាសន៍របស់សាក្សីទីពីរនាសប្តាហ៍នេះ គឺលោក **សំ សិទ្ធី** (អត្តលេខ SCW-3) ដែលមាននៅក្នុងសាលក្រមរបស់ខ្លួន ពាក់ព័ន្ធនឹងការរស់រានមានជីវិតរបស់គាត់ពីការកាប់សម្លាប់យ៉ាងរង្គាលទៅលើទាហាន **លន់ នល់** និងក្រុមគ្រួសាររបស់ពួកគាត់ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចធ្វើការស្តាប់សក្ខីកម្មរបស់គាត់ដោយផ្ទាល់។ ក្រុមមេធាវីការពារក្តីឲ្យលោក **នួន ជា** បានរៀបរាប់ថា ការកោះហៅសាក្សីទីបីឲ្យបង្ហាញខ្លួន គឺលោក **ទាត់ ធឿន** (អត្តលេខ SCW-5) គឺជាសាក្សីគន្លឹះដែលនឹងបំភ្លឺឲ្យកាន់តែច្បាស់នូវចរិតលក្ខណៈនៃក្រុមបំបែកខ្លួនចេញឋានានុក្រមនៃបក្សកុម្មុយនីស្តកម្ពុជា ដោយសារតែគាត់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងលោក **រស់ ញឹម** ដែលជាលេខាបក្សនៅភូមិភាគពាយព្យ។ នៅក្នុងអំឡុងពេលពេញបីថ្ងៃនៃការសួរដេញដោលសាក្សី ភាគីបានមានបំណងលើកឡើងពីការតវ៉ាផ្លូវច្បាប់ជាច្រើន ដែលបានធ្វើការបង្ហាញក្នុងសំណុំរឿង០០២ វគ្គទី១ និងសំណុំរឿង០០២ វគ្គទី២ ដែលភាគច្រើនជាការកត់សម្គាល់នៅក្នុង

---

filed by the deadline on 29 December 2014 but corrected two days later, however, an English translation of the appeal brief has yet to be published

[3] Office of the Co-Prosecutors, "Co-Prosecutors' Appeal Against the Judgment of the Trial Chamber in Case 002/01" (28 November 2014), F11.

[4] Supreme Court Chamber, "Decision on Part of Nuon Chea's Requests to Call Witnesses on Appeal" (29 May 2015), F2/5 [hereinafter **SUPREME COURT CHAMBER DECISION**].

សវនាការធ្វើសន្និដ្ឋានបិទការពិភាក្សាដេញដោលក្នុងសំណុំរឿង០០២ វគ្គទី១ កាលពីខែតុលា ឆ្នាំ២០១៣។[5] ដូចដែលបានធ្វើការកត់សម្គាល់ក្នុងផ្នែកនៃបញ្ហាផ្លូវច្បាប់នៃរបាយការណ៍នេះ ទោះបីជាភាគីបានលើកឡើងនូវការជំទាស់យ៉ាងសំខាន់ៗជាច្រើន ដែលបានផ្លាស់ប្តូរកាលវិភាគដែលបានកំណត់ទុកជាមុនយ៉ាងណាក៏ដោយ ក៏ចៅក្រមបានគ្រប់គ្រងសវនាការយ៉ាងមានប្រសិទ្ធភាព ចំពោះការបញ្ឈប់កិច្ចពិភាក្សាលើផ្នែកណាដែលស្ថិតនៅក្រៅពីវិសាលភាពនៃបណ្តឹងសាទុក្ខ និងសំណុំរឿង០០២ វគ្គទី១ ហើយទទួលបានភាពជោគជ័យលើការទាញយកនូវព័ត៌មានថ្មីៗជាច្រើនចេញពីការសួរដេញដោលសាក្សីទាំងបីរូបនេះផងដែរ។ របាយការណ៍ខាងក្រោមនេះបង្ហាញពីប្រវិត្តនីតិវិធិនៃការសវនាការលើបណ្តឹងសាទុក្ខ ការសង្ខេបស្តីពីសប្តាហ៍នៃសក្ខីកម្មរបស់សាក្សី និងការវិភាគលើសេចក្តីជំទាស់នានា ដែលបង្ហាញពីការពិភាក្សាទំនងជាបានលិចឡើងសាជាថ្មី ក្នុងអំឡុងពេលពេញនៃកិច្ចដំណើរការនីតិវិធីសវនាការលើដំណាក់ការនៃបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២ វគ្គទី១នេះ។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ដាវីដ យូហិន (David Cohen), លីលៀន ហ្គីល (Lillian Gill), លៀ ហ៊ូប៊ើ (Lea Huber), លី ហួតផេង, ដាញ៉ែល ម៉ាតថេស៍ (Daniel Mattes), តាយ លីណា និង វង្ស ឧត្តម ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមនិងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី(AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់បែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (WSD Handa Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University

---

[5] *See* relevant CASE 002/01 KRT TRIAL MONITOR reports on the October 2013 closing statements in Case 002/01: CASE 002/01 KRT TRIAL MONITOR, Issue 70, Hearings on Closing Statements Week 1 (16-18 October 2013); CASE 002/01 KRT TRIAL MONITOR, Issue 71, Hearings on Closing Statements Week 2 (21-25 October 2013); CASE 002/01 KRT TRIAL MONITOR, Issue 72, Hearings on Closing Statements Week 3 (28-31 October 2013).